ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ១៩៦ ក.ប/ប្រ.ក

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌការងារ វិធានអនាម័យ និងសន្តិសុខការងារ នៃសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្សាន្ត

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១០៥/00៣ ចុះថ្ងៃទី១៧ ខែមករាឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញប្រកាសរួមលេខ១០០៩ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញប្រកាសលេខ១៧៦ កប.ប្រក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការអប់រំអនាម័យ និងបច្ចេកទេសសន្តិសុខការងារដល់កម្មករនិយោជិត ប្រតិភូបុគ្គលិក និងសហជីព
- យោងស្មារតីកិច្ចប្រជុំគណៈកម្មការប្រឹក្សាការងារនាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៤
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

### ប្រការ ១.- គោលបំណង គោលដៅ និងវិសាលភាព

ប្រកាសនេះមានគោលបំណងកំណត់ឱ្យនិយោជកនៃសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្សាន្តអនុវត្តច្បាប់ស្តីពីការងារឱ្យបានត្រឹមត្រូវគ្រប់ជ្រុងជ្រោយ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

ប្រកាសនេះមានគោលដៅដូចតទៅ៖

- ពង្រឹងការអនុវត្តច្បាប់ស្តីពីការងារដោយគ្មានការរើសអើង

- បញ្ជាក់ច្បាស់អំពីកាតព្វកិច្ចត្រូវអនុវត្តច្បាប់ស្តីពីការងារ ពីសំណាក់និយោជកចំពោះកម្មករនិយោជិតផ្នែកសេវាកម្សាន្ត

- ផ្តល់ដល់កម្មករនិយោជិតផ្នែកសេវាកម្សាន្ត ឱ្យយល់ជ្រួតជ្រាបអំពីភារកិច្ច សិទ្ធិ និងផលប្រយោជន៍ដែលមានចែងក្នុងច្បាប់ស្តីពីការងារ

- ធ្វើឱ្យទំនាក់ទំនងរវាងនិយោជក និងកម្មករនិយោជិត ផ្នែកសេវាកម្សាន្ត បានល្អប្រសើរស្របតាមច្បាប់ស្តីពីការងារ។

ប្រកាសនេះមានវិសាលភាពអនុវត្តទៅលើសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្សាន្តទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ២.- និយមន័យនៃវាក្យស័ព្ទសំខាន់ៗ

វាក្យស័ព្ទសំខាន់ៗដែលមានប្រើក្នុងប្រកាសនេះ មាននិយមន័យដូចតទៅ៖

- សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្សាន្ត សំដៅដល់សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផលិត ឬបោះដុំ ឬលក់រាយនូវភេសជ្ជៈគ្រប់ប្រភេទ សណ្ឋាគារ ភោជនីយដ្ឋាន ផ្ទះសំណាក់ ខារ៉ាអូខេ ឌីស្កូតែក ក្លឹបកម្សាន្ត បៀរហ្គាឌិន កាស៊ីណូ កន្លែងម៉ាស្សា មណ្ឌលកម្សាន្តនៃទេសចរណ៍វប្បធម៌ ឬធម្មជាតិជាដើម

- និយោជកផ្នែកសេវាកម្សាន្ត សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលសាធារណៈ ឬឯកជនដែលមានបើកសហគ្រាសគ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្សាន្ត ហើយដែលមានប្រើកម្មករនិយោជិតចាប់ពីម្នាក់ឡើងទៅ ទោះបីកម្មករនិយោជិតនោះធ្វើការមិនជាប់លាប់ក៏ដោយ

- កម្មករ និយោជិតផ្នែកសេវាកម្សាន្ត សំដៅដល់កម្មករនិយោជិតដែលបានចុះកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ជាមួយនិយោជក ឬតំណាងនិយោជកនៃសហគ្រាសគ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្សាន្ត

- ភេសជ្ជៈគ្រប់ប្រភេទ សំដៅដល់ស្រាគ្រប់មុខ ស្រាបៀរ ទឹកក្រូច សូដា ទឹកបរិសុទ្ធទឹកផ្លែឈើជាដើម។

## ប្រការ ៣.- កាតព្វកិច្ចអនុវត្តច្បាប់ស្តីពីការងារ

និយោជក ឬតំណាងនិយោជកសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្សាន្ត ត្រូវតែអនុវត្តបទប្បញ្ញត្តិអំពីលក្ខខណ្ឌការងារ វិធានអនាម័យ និងសន្តិសុខការងារ ព្រមទាំងបទប្បញ្ញត្តិដទៃទៀត ដែលមានចែងក្នុងច្បាប់ស្តីពីការងារចំពោះកម្មករនិយោជិតផ្នែកសេវាកម្សាន្តរបស់ខ្លួន។

និយោជក ឬតំណាងនិយោជកនៃសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផលិត ឬបោះដុំ ឬលក់រាយភេសជ្ជៈគ្រប់ប្រភេទ ត្រូវតែអនុវត្តបទប្បញ្ញត្តិអំពីលក្ខខណ្ឌការងារ វិធានអនាម័យ សន្តិសុខការងារ និងបទប្បញ្ញត្តិដទៃទៀត ដែលមានចែងក្នុងច្បាប់ស្តីពីការងារ ព្រមទាំងប្រកាសនានាស្តីពីសុខភាពសន្តិសុខការងារ ចំពោះកម្មករនិយោជិតផ្នែកសេវាកម្សាន្តរបស់ខ្លួន ទោះបីកម្មករនិយោជិតទាំងនោះត្រូវបានបញ្ជូនឱ្យទៅលក់ ឬផ្សព្វផ្សាយលក់ភេសជ្ជៈគ្រប់ប្រភេទនៅតាមសណ្ឋាគារ ភោជនីយដ្ឋាន

ផ្ទះសំណាក់ ខារ៉ាអូខេ ឌីស្កូតែក ក្លឹបកម្សាន្ត បៀរហ្គាឌិន កាស៊ីណូ កន្លែងម៉ាស្សា មណ្ឌលកម្សាន្តនៃទេសចរណ៍វប្បធម៌ ឬធម្មជាតិជាដើមក៏ដោយ។

## ប្រការ ៤.- ភារកិច្ច សិទ្ធិ និងផលប្រយោជន៍

កម្មករនិយោជិតផ្នែកសេវាកម្សាន្ត ត្រូវអនុវត្តការងារតាមការប្រគល់ភារកិច្ចសមស្របពីសំណាក់និយោជក ឬតំណាងនិយោជកផ្នែកសេវាកម្សាន្តរបស់ខ្លួន ហើយត្រូវទទួលបានសិទ្ធិ និងផលប្រយោជន៍ដែលមានចែងក្នុងច្បាប់ស្តីពីការងារដូចកម្មករនិយោជិតដទៃទៀតដែរ។

## ប្រការ ៥.- ពេលម៉ោងធ្វើការ និងការងារលើសម៉ោង

និយោជក ឬតំណាងនិយោជកផ្នែកសេវាកម្សាន្ត ត្រូវតែកំណត់ពេលម៉ោងធ្វើការឱ្យបានច្បាស់លាស់ដល់កម្មករនិយោជិតផ្នែកសេវាកម្សាន្តរបស់ខ្លួន។ រយៈពេលធ្វើការអតិបរមារបស់កម្មករនិយោជិតផ្នែកសេវាកម្សាន្ត គឺ៨ (ប្រាំបី) ម៉ោង ក្នុងមួយថ្ងៃ ឬ៤៨ (សែសិបប្រាំបី) ម៉ោង ក្នុងមួយសប្តាហ៍។

ការដាក់ឱ្យកម្មករនិយោជិតផ្នែកសេវាកម្សាន្តធ្វើការលើសរយៈពេលធ្វើការអតិបរមា ដូចមានចែងក្នុងកថាខណ្ឌទី១នៃប្រការនេះ និយោជក ឬតំណាងនិយោជកផ្នែកសេវាកម្សាន្ត ត្រូវផ្អែកតាមគោលការណ៍ស្ម័គ្រចិត្ត និងផ្តល់ប្រាក់ឈ្នួលបន្ថែមម៉ោង ដល់សាមីខ្លួនកម្មករនិយោជិតដែលបានធ្វើការលើសម៉ោងនោះ តាមបទប្បញ្ញត្តិជាធរមាន។

## ប្រការ ៦.- ការមិនផ្តល់ប្រាក់ឈ្នួលចំពោះរយៈពេលមិនបានបំពេញការងារ និងវិន័យ

កម្មករនិយោជិតផ្នែកសេវាកម្សាន្ត ដែលអវត្តមានពីការងារដោយអត់ច្បាប់ ឬមកធ្វើការយឺត នឹងត្រូវទទួលបានប្រាក់ឈ្នួលដែលសមាមាត្រទៅនឹងរយៈពេលវត្តមានប៉ុណ្ណោះ ។ ក្នុងករណីនេះ និយោជកអាចផ្តល់ប្រាក់ឈ្នួលពេញដល់កម្មករនិយោជិតទាំងនោះ។

និយោជក ឬតំណាងនិយោជកផ្នែកសេវាកម្សាន្តដែលចង់ដាក់វិន័យផ្សេងៗ ទៅលើកម្មករនិយោជិតផ្នែកសេវាកម្សាន្តត្រូវចែងអំពីវិន័យទាំងនោះនៅក្នុងបទបញ្ជាផ្ទៃក្នុងនៃសហគ្រាសគ្រឹះស្ថានក្រុមហ៊ុនរបស់ខ្លួន ឬចែងក្នុងអនុសញ្ញារួមនៃការងារ។

ការដាក់វិន័យជាការកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតផ្នែកសេវាកម្សាន្ត ត្រូវបានហាមឃាត់វៀរលែងតែមានបដិប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីការងារ។

ការបញ្ឈប់កម្មករនិយោជិតផ្នែកសេវាកម្សាន្តពីការងារ ត្រូវតែអនុវត្តទៅតាមបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីការងារ។

## ប្រការ ៧.- ការងារដោយបង្ខំ

បុគ្គលណាក៏ដោយ មិនអាចយកការងារដោយបង្ខំ ទៅប្រគល់ឱ្យកម្មករនិយោជិតផ្នែកសេវាកម្សាន្តអនុវត្តទេដូចជា ការបង្ខំ ឬប្រើមធ្យោបាយបង្ខំកម្មករនិយោជិតផ្នែកសេវាកម្សាន្តឱ្យធ្វើការលើសម៉ោង ឬផឹកគ្រឿងស្រវឹង ឬប្រើគ្រឿងញៀន ឬរំលូតកូន ជាដើម។

## ប្រការ ៨.- អំពើហិង្សា និងប្រទូស្តកេរខ្មាស

បុគ្គលណាក៏ដោយ មិនអាចប្រើអំពើហិង្សា ឬប្រទូស្តកេរខ្មាសទៅលើកម្មករនិយោជិតផ្នែក

សេវាកម្សាន្តឡើយ។

**ប្រការ ៩.- ការអប់រំ បណ្តុះបណ្តាលអំពីសុខភាព និងអនាម័យការងារ**

និយោជក ឬតំណាងនិយោជកផ្នែកសេវាកម្សាន្ត ត្រូវអនុញ្ញាតឱ្យកម្មករនិយោជិតផ្នែកសេវាកម្សាន្តរបស់ខ្លួនទៅទទួលការអប់រំបណ្តុះបណ្តាលអំពីសុខភាព ការទទួលសេវាសុខភាព និងអនាម័យការងារ ដូចមានចែងក្នុងប្រកាសរួមលេខ ១០០៩ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០១២ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងប្រកាសលេខ ១៧៦ កប.ប្រក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការអប់រំអនាម័យ និងបច្ចេកទេសសន្តិសុខការងារដល់កម្មករនិយោជិត ប្រតិភូបុគ្គលិក និងសហជីព។

សាមីខ្លួនកម្មករនិយោជិតផ្នែកសេវាកម្សាន្ត ដែលបានទទួលការអប់រំបណ្តុះបណ្តាលអំពីសុខភាព និងអនាម័យការងារនឹងទទួលបានវិញ្ញាបនបត្របញ្ជាក់អំពីការអប់រំបណ្តុះបណ្តាលនេះ ដើម្បីទុកជាសក្ខីភាពបញ្ជាក់ពីការបានបំពេញកាតព្វកិច្ចត្រឹមត្រូវ ពីសំណាក់និយោជកផ្នែកសេវាកម្សាន្ត។

**ប្រការ ១០.- ទោសទណ្ឌ**

បុគ្គលដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលការផ្តន្ទាទោស ដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

**ប្រការ ១១.- និរាករណ៍បទប្បញ្ញត្តិផ្ទុយ**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១២.- អានុភាពអនុវត្ត**

ប្រកាសនេះមានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០១៤

រដ្ឋមន្ត្រី

អ៊ិត សំហេង

**កន្លែងទទួល ៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
-សាលារាជធានី ខេត្ត
" ដើម្បីជូនជ្រាប "
-គ្រប់អង្គភាពក្រោមឱវាទក្រសួង
-និយោជក
-សហជីព
" ដើម្បីផ្សព្វផ្សាយ និងអនុវត្ត "
-គ្រប់បណ្តាញវិទ្យុ ទូរទស្សន៍
" ដើម្បីជួយផ្សព្វផ្សាយ "
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ